**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ :...០៤៩...សប្រក

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ផលប៉ះពាល់លើតំបន់ និងជនស៊ីវិលកម្ពុជា
# ដោយអំពើឈ្លានពានទាត់ទឹកដីរបស់រដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ
# ពីម៉ោង៦ល្ងាច ថ្ងៃទី១៩ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥

គិតពីថ្ងៃទី៧ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥នេះ **អំពើឈ្លានពានដ៏ឆ្កួតលីលា និងស្មោកគ្រោកបំផុតរបស់រដ្ឋាភិបាលក្រុងបាងកក និងពួកយោធាថៃ** លើដែនអធិបតេយ្យកម្ពុជា ដោយមិនរើសគោលដៅ ជាពិសេសការផ្លោង និងទម្លាក់គ្រាប់តូចធំគ្រប់ប្រភេទចូលតំបន់ស៊ីវិល បានបណ្តាលឱ្យប្រជាពលរដ្ឋកម្ពុជាស្លាប់១៨នាក់ របួស៧៩នាក់ ខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមានជនភៀសសឹកទៅកាន់តំបន់សុវត្ថិភាពរៀបចំដោយអាជ្ញាធរមូលដ្ឋាន ទាំងនៅក្នុងខេត្តរងការឈ្លានពាន និងបណ្តាខេត្តផ្សេងៗទៀត។ **គិតពីម៉ោង៦ល្ងាច ថ្ងៃទី១៩ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី២០ ខែធ្នូ ផលប៉ះពាល់មានដូចខាងក្រោម៖**

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានពលរដ្ឋស្លាប់ និងរបួសថ្មីទេ។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖** មានជនភៀសសឹកសរុប **៥១២,០១០នាក់** ក្នុងនោះស្ត្រី **២៦៧,៤២៨នាក់** និងកុមារ១៦២.២៥៦នាក់។ តួលេខនេះ អាចមានការប្រែប្រួលជាបន្តបន្ទាប់ទៀត។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖ ខូចខាតរថយន្ត១គ្រឿង និងស្ពានថ្ម១កន្លែង** ដែលភ្ជាប់រវាងខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។ ដូច្នេះ ជាបឋម គិតពីថ្ងៃទី៧ ខែធ្នូមក ការខូចខាតសរុបមាន ផ្ទះប្រជាពលរដ្ឋ៧៦ខ្នង សាលារៀន១ទីតាំង មណ្ឌលសុខភាព១ទីតាំង ប្រាសាទបុរាណ១ វត្តអារាម៤ទីតាំង សាលាឆទាន១ទីតាំង កុដិព្រះសង្ឃ១ទីតាំង អគារការិយាល័យគយ និងរដ្ឋាករចំនួន១អគារ អគារឯកជន៨ទីតាំង សណ្ឋាគារ៣ទីតាំង មណ្ឌលកសិកម្មសហគមន៍១ទីតាំង ស្ពានថ្ម២កន្លែង ស្ពានដែក១ ស្ពានបុរាណ១កន្លែង ក្បាលស្ពាន១កន្លែង ស្ថានីយ៍ប្រេង១ទីតាំង មធ្យោបាយដឹកជញ្ជូន២៦គ្រឿង ឃ្លាំងរថយន្ត១ និងឃ្លាំងទិញដំឡូង១ទីតាំង ។ ក្រៅពីនេះ សេវាជាមូលដ្ឋាន ដូចជា រដ្ឋបាល សុខាភិបាល និងអប់រំតាមក្រុង ស្រុក ឃុំ-សង្កាត់ ក៏បានផ្អាកស្ទើរទាំងស្រុង ដោយសារតែភាគីថៃបង្កើនការវាយប្រហារមកលើតំបន់ស៊ីវិល ទាំងតាមជើងគោក ជើងទឹក និងជើងអាកាស។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមយកឱកាសនេះសង្កត់ធ្ងន់ថា កម្ពុជា បានហែលឆ្លងកាត់សោកនាដកម្មនៃភ្លើងសង្គ្រាមជាច្រើនឆ្នាំមកហើយ។ ពេលនេះ ប្រជាជនកម្ពុជាកន្លះលាននាក់ រួមទាំងស្ត្រី និងកុមារ កំពុងទទួលរងទុក្ខលំបាក ព្រោះតែការបង្ខំចិត្តចាកចោលផ្ទះសំបែង និងសាលារៀន ដើម្បីគេចពីគ្រាប់កាំភ្លើង គ្រាប់ផ្លោងតូចធំ និងការទម្លាក់គ្រាប់បែកពីយន្តហោះ F16 របស់ថៃ ដែលបានកំពុងបំផ្លាញផ្ទះសំបែង និងភូមិករពួកគាត់ជាបន្តបន្ទាប់រួចទៅហើយ។ ប្រជាពលរដ្ឋកម្ពុជា មិនអាចទទួលយកបានជាដាច់ខាត ចំពោះអំពើឈ្លានពាន ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើយង់ឃ្នងផ្សេងៗបង្កឡើងដោយរដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ។ ទន្ទឹមនឹងការប្តូរផ្តាច់ប្រយុទ្ធការពារបូរណភាពទឹកដី ស្របតាមច្បាប់អន្តរជាតិ យើងសូមទទូចជាថ្មីទៀត/

ទៅកាន់សហគមន៍អន្តរជាតិ និងមជ្ឈដ្ឋានផ្ទៃក្នុងថៃ ដែលមានភាពស៊ីវិល័យ ថ្លៃថ្នូរ និងដឹងខុសត្រូវ រួមគ្នាថ្កោលទោស និងមានចំណាត់ការវិជ្ជមានជាបន្ទាន់ ដើម្បីឱ្យតួអង្គក្នុងរដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ មានសតិសម្បជញ្ញៈជាមនុស្ស បញ្ឈប់សង្គ្រាមឈ្លានពានកម្ពុជា ខិតខំរួមគ្នាអនុវត្តបទឈប់បាញ់ តាមកិច្ចព្រមព្រៀងដែលមានសហរដ្ឋអាមេរិក ចិន និងម៉ាឡេស៊ី ជាអ្នកសម្របសម្រួល ជួយជ្រោមជ្រែង និងជាសាក្សី។

**ក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា** មានមោទនភាព និងកត់ត្រាទុកនូវកម្លាំងមហាសាមគ្គីជាតិកំពុងមានចលនាកាន់តែសកម្មរឹងមាំខ្ពស់ត្រដែត ដោយកូនខ្មែរគ្រប់រូប នៅគ្រប់ទីកន្លែងទូទាំងពិភពលោក បានវេញស្មារតីជាតិជាធ្លុងមួយ ប្រកៀកស្មាគាំទ្រ និងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**។ មហាកម្លាំងសាមគ្គីនេះ បានផ្តល់ថាមពលដ៏មហិមាជូនដល់កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែននៃក្រសួងមហាផ្ទៃ ដែលកំពុងកៀកស្មាប្រយុទ្ធការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ប្រកបដោយម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅសមរភូមិ។

ថ្ងៃសៅរ៍ ១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥